**LOWELL PUBLIC SCHOOLS**
***អគាររដ្ឋបាល** Henry J. Mroz*

*155 Merrimack Street*
*Lowell, Massachusetts 01852*

*Lisa Van Thiel*
***អ្នកសម្របសម្រួលមុនកុមារភាព***
*978-674-2051*
*lvanthiel@lowell.k12.ma.us*

# សូមយកចិត្តទុកដាក់

# សាលាឯកជន/ឪពុកម្តាយបង្រៀននៅផ្ទះ
# ស្វែងរកកុមារ

Lowell Public Schools មានទំនួលខុសត្រូវ ដើម្បីកំណត់អត្តសញ្ញាណកុមារណាម្នាក់ដែលអាចនឹងមានពិការភាព ដែលជាអ្នករស់នៅ Lowell ឬ អ្នកដែលបានចូលរៀនសាលាឯកជន ក្នុងតំបន់ភូមិសាស្រ្ត Lowell ទោះបីជាសិស្សមិនមែនជាអ្នករស់នៅ Lowell ក៏ដោយ។ នេះក៏រាប់បញ្ចូលទាំងសិស្សដែលរៀននៅផ្ទះផងដែរ។

Lowell Public Schools ក៏ទទួលខុសត្រូវផងដែរចំពោះការវាយតម្លៃសិស្សទាំងនោះ ដើម្បីកំណត់ថាតើពួកគេមានសិទ្ធិទទួលបានការអប់រំពិសេស ឬ សេវាកម្មពាក់ព័ន្ធក្រោមច្បាប់សហព័ន្ធ IDEA (ច្បាប់ស្តីពីការអប់រំជនពិការ) ឬច្បាប់រដ្ឋ Massachusetts 603 CMR (បទបញ្ជាអប់រំពិសេសនៃរដ្ឋ Massachusetts)។

Lowell Public Schools ក៏ប្តេជ្ញាកំណត់អត្តសញ្ញាណកុមារមុនអាយុ 3 ឆ្នាំដើម្បីផ្តល់សេវាកម្មអន្តរាគមន៍ជាមុន សម្រាប់កុមារពិការអាយុ 3 និង 4 ឆ្នាំ។ ប្រសិនបើអ្នកមានសំណួរឬកង្វល់ទាក់ទងនឹងការលូតលាស់របស់កូនអ្នក ហើយចង់អោយគាត់ទទួលបានការពិនិត្យ សូមបំពេញតាមអ៊ិនធឺណែតសម្រាប់ការស្នើសុំការពិនិត្យការលូតលាស់។ ការពិនិត្យធ្វើឡើងដោយការណាត់ជួបតែប៉ុណ្ណោះ។ នៅពេលដែលអ្នកបានផ្ញើទម្រង់បែបបទតាមអ៊ិនធឺណែត សមាជិកម្នាក់នៃបុគ្គលិក នាយកដ្ឋានមុនកុមារភាព (Early Childhood Department) នឹងទាក់ទងអ្នកដើម្បីតាមដានសំណួរណាមួយនិងកំណត់ពេលណាត់ជួប។ ប្រសិនបើអ្នកមានសំណួរ សូមទាក់ទងនាយកដ្ឋានមុនកុមារភាពលេខ 978-674-2050។

ប្រសិនបើអ្នកសង្ស័យថា កូនរបស់អ្នកអាចត្រូវការវាយតម្លៃដើម្បីកំណត់សិទ្ធិទទួលសេវាកម្មអប់រំពិសេស អ្នកអាចស្នើសុំការវាយតម្លៃដោយមិនគិតថ្លៃតាមរយៈ Lowell Public Schools ការិយាល័យអប់រំពិសេស (Special Education Office)។ សូមផ្ញើសំណើរបស់អ្នកទៅ LPSSpedReferrals@lowell.k12.ma.us។ ប្រសិនបើអ្នកមានសំណួរទាក់ទងនឹងដំណើរការវាយតំលៃ សូមទាក់ទងនាយកដ្ឋានអប់រំពិសេស (Special Education Department) អាសយដ្ឋាន155 Merrimack Street, 5th Floor, Lowell, MA ឬទូរស័ព្ទមក 978-674-4322 ។

*សេចក្តីជូនដំណឹងនេះត្រូវបានផ្តល់ជូនស្របតាមបទប្បញ្ញត្តិរបស់រដ្ឋនិងសហព័ន្ធ សម្រាប់សកម្មភាពស្វែងរកកុមារដើម្បីកំណត់អត្តសញ្ញាណសិស្ស ដែលប្រហែលជាត្រូវការការវាយតម្លៃដើម្បីកំណត់សិទ្ធិទទួលបានសេវាកម្មអប់រំពិសេស។*